ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ✓ ព.ណ............

# សេចក្តីអំពាវនាវ
# ស្តីពី
# ការរក្សាថ្លៃទំនិញលើទីផ្សារ ក្នុងព្រះរាជាណាចក្រកម្ពុជា

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជន ឲ្យបានជ្រាបថា បន្ទាប់ពីក្រសួងសុខាភិបាលបានប្រកាសក្នុងសន្និសីទសារព័ត៌មានស្តីពីការរកឃើញករណីមេរោគ Covid-19 លើបុរសជនជាតិខ្មែរមួយរូបនៅខេត្តសៀមរាប ក្រសួងពាណិជ្ជកម្មបានសង្កេតឃើញថា ម្ចាស់ហាងលក់ទំនិញធំៗ បងប្អូនអាជីវករ អ្នកលក់ដូរទំនិញទូទៅភាគច្រើន នៅរក្សាការផ្គត់ផ្គង់ទំនិញ និងបន្តលក់ទំនិញតាមតម្លៃធម្មតា ទោះបីមានប្រជាពលរដ្ឋមួយចំនួនសម្រុកទិញទំនិញច្រើនខុសប្រក្រតីក៏ដោយ។ ក្រសួងពាណិជ្ជកម្ម សូមសម្តែងនូវការកោតសរសើរ និងលើកទឹកចិត្តចំពោះម្ចាស់ហាងទំនិញ និងបងប្អូនអាជីវករទាំងនោះជាខ្លាំង។

ក្នុងពេលជាមួយគ្នានេះដែរ មានហាងលក់ទំនិញមួយចំនួនតូច បានឆ្លៀតឱកាសលក់ដំឡើងថ្លៃទំនិញ ដូចជា ម៉ាស់ការពារមុខ អាកុលលាងដៃ និងទំនិញចាំបាច់មួយចំនួនទៀត ដែលសកម្មភាពទាំងនេះអាចបង្កឲ្យមានចលាចលក្នុងសង្គមធ្ងន់ធ្ងរ។

ក្នុងស្ថានភាពនេះ ក្រសួងពាណិជ្ជកម្មសូមជម្រាបជូន និងអំពាវនាវ ដូចខាងក្រោម៖

១. សូមប្រជាពលរដ្ឋមេត្តាជ្រាបថា បរិមាណសន្និធិអង្ករ និងស្រូវមិនទាន់កិនដែលមានក្នុងប្រទេស អាចធានាដល់ការប្រើប្រាស់ក្នុងស្រុក និងនាំចេញទៅក្រៅប្រទេសទៀតផង (សេចក្តីប្រកាសព័ត៌មានរបស់សហព័ន្ធស្រូវអង្ករកម្ពុជា និងក្រុមហ៊ុនគ្រឿនគ្រេដ នៃក្រសួងពាណិជ្ជកម្ម)។

២. សូមប្រជាពលរដ្ឋមេត្តារក្សានូវភាពហ្មឹងនរ កុំជ្រួលច្របល់ហួសហេតុ នាំឲ្យជនឱកាសនិយម អាចឆ្លៀតយកចំណេញ តាមរយៈការលក់ដំឡើងថ្លៃទំនិញដោយមិនសមហេតុសមផល។

៣. សូមម្ចាស់ហាងទំនិញទូទៅ ប្រកាន់នូវស្មារតីសាមគ្គីជាតិខ្មែរ កុំឆ្លៀតឱកាសដំឡើងថ្លៃទំនិញស្រេចតែអំពើចិត្ត។ ក្នុងករណីរកឃើញភាពមិនប្រក្រតី អាជ្ញាធរមានសមត្ថកិច្ចនឹងចាត់វិធានការតាមផ្លូវច្បាប់។

សូមជម្រាបជូនផងដែរថា ក្រសួងពាណិជ្ជកម្ម បាន និងកំពុងសហការជាមួយស្ថាប័នផ្សេងទៀត ចាត់វិធានការសមស្រប ដើម្បីធានានូវចរាចរទំនិញទូទៅ និងការផ្គត់ផ្គង់គ្រឿងឧបភោគបរិភោគចាំបាច់ សម្រាប់បម្រើជីវភាពរបស់ប្រជាជនយើងនៅក្នុងកាលៈទេសៈនេះ។ ក្រសួងពាណិជ្ជកម្មនឹងចាត់មន្ត្រីជំនាញ ឲ្យសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធចុះស្រាវជ្រាវ និងត្រួតពិនិត្យគុណភាព សុវត្ថិភាពទំនិញ ព្រមទាំងដាក់ចេញនូវវិធានការផ្លូវច្បាប់ ក្នុងករណីរកឃើញ ជនខិលខូចដែលឆ្លៀតឱកាសលក់ទំនិញឡើងថ្លៃ កេងចំណេញជ្រុលហួសហេតុ។

ក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ហាងទំនិញ បងប្អូនអាជីវករ និងប្រជាពលរដ្ឋយើង ចូលរួមអនុវត្តតាមសេចក្តីអំពាវនាវនេះ ក្នុងគោលដៅអនុវត្តច្បាប់ជាធរមានផង និងបង្ហាញពីស្មារតីសាមគ្គីជាតិខ្មែរ ខ្មែរជួយខ្មែរ ក្រោមដំបូលសន្តិភាព ដែលប្រជាពលរដ្ឋយើងកំពុងទទួលបានផង។

ថ្ងៃចន្ទ ១រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០